ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
*******
សំណុំរឿងរដ្ឋប្បវេណីលេខ: ៨៥
ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០
សាលក្រមរដ្ឋប្បវេណីលេខ:៨៩ «ង»
ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០២០

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី២៤-០៨-២០២០។

**ចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូង

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

-ដើមចោទឈ្មោះ [redacted] ចាន់ថុល ភេទស្រី អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted]។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted]។

-សហចុងចម្លើយ:

១.ឈ្មោះ [redacted] ភត្រា ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted]

២.ឈ្មោះ [redacted] គុយអេង ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted]

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] និងលោកមេធាវី [redacted]។

៣.ឈ្មោះ [redacted] ភក្តី ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted]។

**អង្គហេតុ និងចំណុចវិវាទ**

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ:**

១.សុំមោឃភាពលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ របស់ឈ្មោះ [redacted] តម និងប្រពន្ធឈ្មោះ [redacted] ឃឿន លក់ដីឲ្យឈ្មោះ [redacted] គុយអេង និងសុំមោឃភាពលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ របស់ឈ្មោះ [redacted] ស៊ីណុន និងប្តីឈ្មោះ [redacted] សារិន លក់ដីឲ្យឈ្មោះ [redacted] គុយអេង។

២.សុំសិទ្ធិគ្រប់គ្រងដីចំនួន ២កន្លែង:

-ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ ចុះថ្ងៃទី ១២-០៧-២០០៦ មានទំហំ ៧៤៥ម² ស្ថិតនៅភូមិសំពៅង ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលមានកិច្ចសន្យាផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១០-១០-២០១៥ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី១៦-០២-២០១៥។



Scanned with CamScanner

-ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ ចុះថ្ងៃទី ១២-០៧-២០០៦ មានទំហំ ៥០៨ម² ស្ថិតនៅភូមិសំពៅង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលមានកិច្ចសន្យាផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១០-១០-២០១៥ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីចុះថ្ងៃទី១៦-០២-២០១៥។

៣.សុំទាមទារឲ្យសហចុងចម្លើយបង់ជម្ងឺចិត្ត និងសេវាកម្មច្បាប់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**ចុងចម្លើយបានប្តឹងទាមទារ:**

១.ច្រានចោលការទាមទារដែលមាននៅក្នុងពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចាន់ថុល ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ចោលជាអសាបង់។

២.ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភក្តី ដែលបានលក់ដីមកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] តុយអេង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:០៥០៧០៥១៨-០៥៥០ មានទំហំ៥០៨ម² មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

៣.ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភក្តី ដែលបានលក់ដីមកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] តុយអេង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ ៧៤៥ ម² មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

៤.ប្រគល់ដីចំនួន០២កន្លែង ដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ មានទំហំ៥០៨ម² និងដីមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ៧៤៥ម² មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] តុយអេង ជាអ្នកគ្រប់គ្រង។

៥.ទាមទារឲ្យចុងចម្លើយបណ្តឹងតបសងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន ៨០,០០០,០០០ (ប៉ែតសិបលាន)រៀល។

៦.ឲ្យចុងចម្លើយបណ្តឹងតបជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

**ខ.ដំណើររឿងក្តី និងចំណុចវិវាទ:**

ខ.១.**ការសង្ខេបអំពីរឿងក្តី**:ក្នុងរឿងក្តីនេះ ដើមចោទប្តឹងសុំមោឃភាពលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩.មោឃភាពលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ចុះ ថ្ងៃទី១២-០៩-២០១៩ សុំសិទ្ធិគ្រប់គ្រងដីចំនួន ២កន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ ចុះថ្ងៃទី១២-០៧-២០០៦ មានទំហំ ៧៤៥ម² និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់រចលនវត្ថុលេខ: ០៥០៧០៥១៨ -០៥៥០ ចុះថ្ងៃទី១២-០៧-២០០៦ មានទំហំ ៥០៨ម² ស្ថិតនៅភូមិសំពៅង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដោយសារកាលពីថ្ងៃទីខែមិនចាំឆ្នាំ២០១៤ ឈ្មោះ [redacted] ភក្តី បានខ្ចីប្រាក់ពីឈ្មោះ [redacted] ចាន់ថុល ចំនួន ១.៥០០$ (មួយពាន់ប្រាំរយដុល្លារអាមេរិក) ដោយគ្មានប្រាក់សងឈ្មោះ [redacted] ភក្តី បានឲ្យឈ្មោះ [redacted] ចាន់ថុល ទិញដីចំនួន២ កន្លែង ដើម្បីកាត់សងបំណុល ។

ខ.២.ចំណុចវិវាទ:

-មោឃភាពលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ . មោឃភាពលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ និងសុំសិទ្ធិគ្រប់គ្រងដីចំនួន ២កន្លែង ។



Scanned with CamScanner

-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ . លិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ និងប្រគល់ដីចំនួន០២កន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ មានទំហំ៥០៨ម² និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ៧៤៥ម² មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] គុយអេង ជាអ្នកគ្រប់គ្រង ។

**ខ.៣.ការអះអាងរបស់គូភាគី**

**-ការអះអាងរបស់ដើមចោទ:** កាលពីថ្ងៃខែមិនចាំក្នុងឆ្នាំ២០១៤ សហចុងចម្លើយឈ្មោះ [redacted] ភក្តី បានមកខ្ចីប្រាក់ពីដើមចោទចំនួន ១.៥០០$(មួយពាន់ប្រាំរយដុល្លារអាមេរិក) ដោយបានប្រាប់ថាយកទៅដោះទាល់មួយគ្រាសិន ដោយសន្យាសងមកឲ្យវិញក្នុងរយៈពេលមួយខែ។ពេលដល់កំណត់សងប្រាក់បានទៅទារប្រាក់ តែចុងចម្លើយមិនបានសងត្រឡប់មកឲ្យដើមចោទវិញទេ។រហូតដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥ សហចុងចម្លើយបានមកសុំអង្វរដើមចោទឲ្យជួយទិញដី លក់ក្នុងតម្លៃ៣ដុល្លារក្នុង១ម៉ែត្រការ៉េ ដោយសារមានការអង្វរពីសហចុងចម្លើយច្រើនដងពេកដើមចោទក៏សម្រេចចិត្តទិញយកដី ដោយកាត់កងជាមួយបំណុលដែលជំពាក់ចំនួន ១.៥០០$(មួយពាន់ប្រាំរយដុល្លារអាមេរិក) ផងដែរ។តែដីទាំងពីរប្លង់នោះសហចុងចម្លើយបានយកទៅដាក់តម្កល់នៅធនាគារដើម្បីខ្ចីប្រាក់ចំនួន ៥.០០០$ (ប្រាំពាន់ដុល្លារអាមេរិក) ទើបសហចុងចម្លើយបានយកវិញ្ញាបនប័ត្រដីទាំងពីរដែលបានថតចម្លងមកបង្ហាញ ដោយសន្យាថាពេលបង់ធនាគារដាច់នឹងដកប្លង់ច្បាប់ដើមមកប្រគល់ឲ្យដើមចោទ ដោយឮពាក្យអះអាងរបស់សហចុងចម្លើយក៏យល់ព្រមទិញដីទាំងពីរប្លង់ក្នុងតម្លៃសរុប ៣.៧៥៩$ (បីពាន់ប្រាំពីររយហាសិបប្រាំបួនដុល្លារអាមេរិក) ក្នុងទំហំដីសរុបទាំងពីរប័ណ្ណ ១២៥៣ ម៉ែត្រការ៉េ និងបានធ្វើកិច្ចសន្យាផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥ ពីសហចុងចម្លើយមកដើមចោទ ដោយមានអាជ្ញាធរភូមិ ឃុំ ដឹងឮ និងបានធ្វើការអាស្រ័យផលលើដីទាំងពីរប័ណ្ណខាងលើរហូតដល់បច្ចុប្បន្ន។

ស្រាប់តែនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ឈ្មោះ [redacted] មៀក បានមកប្រាប់ថាដីត្រូវបានសហចុងចម្លើយឈ្មោះ [redacted] ភក្តី បានយកលក់បន្តឲ្យទៅសហចុងចម្លើយឈ្មោះ [redacted] គុយអេង និងប្តីឈ្មោះ [redacted] ភត្រា បាត់ហើយ ពេលនោះដើមចោទមិនជឿទេក៏បានទៅសួរលោកមេឃុំព្នាយ លោកមេឃុំព្នាយបានប្រាប់ថាឈ្មោះ [redacted] ភក្តី បានលក់បន្តឲ្យទៅសហចុងចម្លើយឈ្មោះ [redacted] គុយអេង និងប្តីឈ្មោះ [redacted] ភត្រា មែន។ពេលឮដូចនេះបានទៅប្តឹងលោកមេភូមិសំពៅង និងប្រាប់ថាឈ្មោះ [redacted] គុយអេង បានប្រាប់ថាឲ្យចុះហត្ថលេខាដីនោះដោះស្រាយរួចហើយ ។ លោកមេភូមិក៏សួរបញ្ជាក់សហចុងចម្លើយឈ្មោះ [redacted] គុយអេង ថាដីនោះជាដីរបស់ឈ្មោះ [redacted] ចាន់ថុល ប្រយ័ត្នពាក់ព័ន្ធ។ លោកមេភូមិបានហៅឈ្មោះ [redacted] គុយអេង. ឈ្មោះ [redacted] ភត្រា និងឈ្មោះ [redacted] ភក្តី ទៅសួរនាំនៅសាលាឃុំព្នាយ ប៉ុន្តែសហចុងចម្លើយទាំងបីនាក់មិនបានចូលខ្លួនមកដោះស្រាយឡើយ ទើបដើមចោទបានដាក់ពាក្យបណ្តឹងលើឈ្មោះ [redacted] ភក្តី មកស្នងការនគរបាលខេត្តកំពង់ស្ពឺ តែឈ្មោះនេះមិនចូលខ្លួនមកដោះស្រាយឡើយ និងសម្រេចចិត្តដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តកំពង់ស្ពឺ និងសម្រេចច្រានចោលពាក្យបណ្តឹងតបរបស់សហចុងចម្លើយ។

**-ការអះអាងរបស់ចុងចម្លើយ:**

-សហចុងចម្លើយឈ្មោះ [redacted] គុយអេង និងឈ្មោះ [redacted] ភត្រា ធ្វើសេចក្តីថ្លែងការណ៍: កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ សហចុងចម្លើយឈ្មោះ [redacted] គុយអេង និងឈ្មោះ [redacted] ភត្រា បានទិញដី ចំនួន ០២កន្លែង ទី១ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ មានទំហំ ៥០៨ ម² និងទី២ ដីមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ ៧៤៥ ម² មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ពីឈ្មោះ [redacted] ភក្តី ហើយបានធ្វើលិខិតផ្ទេរសិទ្ធ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ ដោយមានការចុះហត្ថលេខា បញ្ជាក់ពីអាជ្ញាធរភូមិឃុំថែមទៀតផង ដោយដីទាំង ០២ (ពីរ) កន្លែង ខាងលើគឺឈ្មោះ [redacted] ភក្តី បានទិញពីម្ចាស់ដីដើម



Scanned with CamScanner

ឈ្មោះ [redacted] ស៊ីណុន មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ មានទំហំ ៥០៨ ម² និងបានទិញពីឈ្មោះ [redacted] តប និងប្រពន្ធឈ្មោះ [redacted] ឃឿន មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ ៧៤៥ ម² មានទីតាំងស្ថិត នៅភូមិសំពៅង ឃុំព្នាយ ស្រុកសំពៅងទង ខេត្តកំពង់ស្ពឺ ដែលមានតម្លៃសរុបចំនួន ១២.៨០០$(មួយម៉ឺនពីរពាន់ប្រាំបីរយដុល្លារអាមេរិក) ដោយសហចុងចម្លើយបានទិញដីនេះតាមរយៈមន្ត្រីបម្រើការងារនៅធនាគារប្រាសាក់ ដោយហេតុថាដីទាំង ០២ ប័ណ្ណខាងលើឈ្មោះ [redacted] ភក្តី បានយកប្លង់ទៅដាក់ធានាដើម្បីខ្ចីប្រាក់នៅធនាគារប្រាសាក់ចំនួនរហូតដល់ទៅ ០២ ដង ដោយលើកទី១ គឺឈ្មោះ [redacted] ភក្តី បានខ្ចីចំនួន ៥.០០០$ (ប្រាំពាន់ដុល្លារអាមេរិក) និងខ្ចីលើកទី២ ចំនួន ៨.០០០$(ប្រាំបីពាន់ដុល្លារអាមេរិក) នៅក្នុងពេលទិញលក់នោះ គឺបានរៀបចំឯកសារផ្ទេរសិទ្ធិ និងលក់ផ្តាច់ត្រឹមត្រូវដោយមានការបញ្ជាក់ដឹងឮពីរាជ្ញាធរភូមិឃុំផងដែរ ហើយសហចុងចម្លើយ បានប្រគល់ប្រាក់នៅចំពោះមុខមន្ត្រីធនាគារប្រាសាក់ ជាច្រើននាក់ និងមានឈ្មោះ [redacted] ថា ដែលជាមន្ត្រីបំរើការងារនៅធនាគារ និងជាអ្នកជួយរៀបចំឯកសារឲ្យសហចុងចម្លើយថែមទៀតផង ។ ក្រោយពីបានប្រគល់ប្រាក់ថ្លៃទិញលក់ដីនោះរួចមក ឈ្មោះ [redacted] ភក្តី បានដកប្លង់ពីធនាគារ និងបានប្រគល់ប្លង់ដីចំនួន ០២កន្លែង ខាងលើនោះ ឲ្យមកសហចុងចម្លើយជាអ្នកកាន់កាប់បន្ត ក្រោយពីទទួលបានប្លង់ដីនោះសហចុងចម្លើយក៏បានរៀបចំឯកសារដើម្បីផ្ទេរកម្មសិទ្ធិពីម្ចាស់ដីដើមដែលមានឈ្មោះ [redacted] តប និងប្រពន្ធឈ្មោះ [redacted] ឃឿន និងម្ចាស់ដីដើមម្នាក់ទៀតឈ្មោះ [redacted] ស៊ីណុន ដើម្បីឲ្យការកាន់កាប់នោះស្របទៅតាមផ្លូវច្បាប់។ ប៉ុន្តែស្រាប់តែលេចវត្តមានឈ្មោះ [redacted] ចាន់ថុល បានមករារាំង និងអះអាងថាជាម្ចាស់ដីទាំងពីរប័ណ្ណខាងលើ ដែលសហចុងចម្លើយបានទិញយ៉ាងត្រឹមត្រូវទៅវិញ។ក្នុងអំឡុងពេលខ្ចីប្រាក់ពីធនាគារនោះឈ្មោះ [redacted] ភក្តី ក៏ធ្លាប់បានខ្ចីចងការប្រាក់ពីដើមចោទឈ្មោះ [redacted] ចាន់ថុល ចំនួន ១.០០០$ (មួយពាន់ដុល្លារអាមេរិក) ផងដែរ ប៉ុន្តែការខ្ចីចងការប្រាក់រវាងឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ចាន់ថុល គឺមិនបានធ្វើកិច្ចសន្យាអ្វីនោះទេ លុះនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥ ក្រោយពេលដែលឈ្មោះ [redacted] ភក្តី មិនមានលទ្ធភាពបង់ការប្រាក់បន្ត ក៏ស្រាប់តែឈ្មោះ [redacted] ចាន់ថុល បានបង្ខំឲ្យឈ្មោះ [redacted] ភក្តី ធ្វើកិច្ចសន្យាផ្ទេរសិទ្ធិ និងលក់ផ្តាច់ និងឱ្យឈ្មោះ [redacted] ភក្តី ធ្វើលិខិតធានាត្រូវយកប្លង់ដីស្រែចំនួន ០២កន្លែងខាងលើនោះឲ្យមកដើមចោទ ហើយលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ព្រមទាំងប្លង់ដីស្រែទាំងពីរខាងលើនេះ គឺឈ្មោះ [redacted] ចាន់ថុល បានអះអាងប្រាប់ទៅឈ្មោះ [redacted] ភក្តី ថាគ្រាន់តែធ្វើដើម្បីមានឯកសារខ្លះចំពោះការខ្ចីប្រាក់តែប៉ុណ្ណោះ ហើយលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់រវាងឈ្មោះ [redacted] ភក្តី និងឈ្មោះ [redacted] ចាន់ថុល នេះ គឺក្រោមរូបភាពជាការខ្ចីប្រាក់នោះទេ។ ក្រោយមកឈ្មោះ [redacted] ចាន់ថុល បានមកប្តឹងអាជ្ញាធរ និងបានដាក់ពាក្យបណ្តឹងមកកាន់សាលាដំបូងខេត្តកំពង់ស្ពឺ ឲ្យប្រគល់ដីទាំង ០២ប័ណ្ណ ខាងលើនេះ ឲ្យគាត់គ្រប់គ្រងទៅវិញ ។ មិនតែប៉ុណ្ណោះ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ឈ្មោះ [redacted] ចាន់ថុល បានឲ្យគេមកភ្ជួរដីស្រែខាងលើ ហើយសហចុងចម្លើយក៏បានទៅប្តឹងអាជ្ញាធរឃុំ ក៏ឈ្មោះ [redacted] ចាន់ថុល នៅតែមិនព្រមបញ្ឈប់សកម្មភាព និងនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ៧:០០ នាទីព្រឹក បានឲ្យគេបូមទឹកដាក់ចូលនៅក្នុងដីស្រែនោះ ទោះបីជាមានក្រុមប្រឹក្សាឃុំ និងមន្ត្រីប៉ុស្តិ៍មកហាមឃាត់ក៏គេនៅតែមិនស្តាប់ដែរ។

-សហចុងចម្លើយឈ្មោះ [redacted] ភក្តី ធ្វើសេចក្តីថ្លែងការណ៍: អវត្តមាន។

## សំអាងហេតុ

១.តាមការអះអាងរបស់ដើមចោទឈ្មោះ ហង់ ចាន់ថុល បញ្ជាក់ថា:ឈ្មោះ [redacted] ភក្តី បានមកខ្ចីប្រាក់ពីដើមចោទចំនួន១.៥០០$(មួយពាន់ប្រាំរយដុល្លារអាមេរិក) ដោយសន្យាសងក្នុងរយៈពេលមួយខែ។ពេលដល់កំណត់សងប្រាក់បានទៅទារប្រាក់ តែសហចុងចម្លើយមិនបានសងត្រឡប់មកឲ្យដើមចោទវិញទេ និងបានមកសុំអង្វរដើមចោទឲ្យជួយទិញដីលក់ក្នុងតម្លៃ៣ដុល្លារក្នុង១ម៉ែត្រការ៉េ ដោយកាត់កងជាមួយ

បំណុលដែលជំពាក់ចំនួន ១.៥០០$(មួយពាន់ប្រាំរយដុល្លារអាមេរិក) និងបានធ្វើកិច្ចសន្យាផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥ ដោយមានអាជ្ញាធរភូមិ ឃុំ ដឹងឮ តែដីទាំងពីរប្លង់នោះឈ្មោះ [redacted] ភក្តី បានយកទៅដាក់តម្កល់នៅធនាគារដើម្បីខ្ចីប្រាក់។

២.តាមការអះអាងរបស់សហចុងចម្លើយឈ្មោះ [redacted] តុយអេង និងឈ្មោះ [redacted] ភត្រា បញ្ជាក់ថាបានទិញ ដីចំនួន ០២ កន្លែង គឺដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ មានទំហំ ៥០៨ ម² និងដីមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ ៧៤៥ ម² មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងបានធ្វើលិខិតផ្ទេរសិទ្ធ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ ដោយមានការចុះហត្ថលេខា បញ្ជាក់ពីអាជ្ញាធរភូមិ ឃុំ តម្លៃសរុបចំនួន ១២.៨០០$(មួយម៉ឺនពីរពាន់ប្រាំបីរយដុល្លារអាមេរិក) ពីឈ្មោះ [redacted] ភក្តី តាមរយៈមន្ត្រីបម្រើការងារនៅធនាគារប្រាសាក់ ។

៣.ចំពោះការទាមទាររបស់ដើមចោទ:

-សុំមោឃភាពលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ . មោឃភាពលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ និងសុំសិទ្ធិគ្រប់គ្រងដីចំនួន ២កន្លែង ។

ចំពោះអង្គហេតុដែលបានអះអាងដោយដើមចោទ ដែលថាបានទិញដីពីឈ្មោះ [redacted] ភក្តី ក្នុងតម្លៃ៣ដុល្លារក្នុង១ម៉ែត្រការ៉េ ដោយកាត់កងជាមួយបំណុលដែលជំពាក់ចំនួន ១.៥០០$ (មួយពាន់ប្រាំរយដុល្លារអាមេរិក) ។

ជាការសន្និដ្ឋានការទាមទារខាងលើ និងការទាមទារគ្រប់ចំនុចរបស់ដើមចោទ ធ្វើឡើងមិនមានមូលហេតុត្រឹមត្រូវតាមច្បាប់ មិនមានអង្គហេតុ និងមិនមានភស្តុតាងបញ្ជាក់គ្រប់គ្រាន់ថាដើមចោទបានទិញដីពីឈ្មោះ [redacted] ភក្តី ដោយដីរបស់ឈ្មោះ [redacted] ភក្តី គឺមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ មានទំហំ ៥០៨ ម² ចុះថ្ងៃទី១២-០៧-២០០៦ និងដីមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ ៧៤៥ ម² ចុះថ្ងៃទី១២-០៧-២០០៦ ការទិញលក់ត្រូវធ្វើតាមនីតិវិធីនៃការផ្ទេរកម្មសិទ្ធិ ។ អ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀងឲ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ។ ហេតុនេះគប្បីតុលាការសម្រេចច្រានចោលការទាមទារទាំងនេះ។

៤.ចំពោះបណ្តឹងតបរបស់សហចុងចម្លើយឈ្មោះ [redacted] តុយអេង និងឈ្មោះ [redacted] ភត្រា ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-ការទាមទារឲ្យទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភក្តី ដែលបានលក់ដីមកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] តុយអេង និងទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភក្តី មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

-ប្រគល់ដីចំនួន០២កន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ មានទំហំ៥០២ម² និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ៧៤៥ម² មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] តុយអេង ជាអ្នកគ្រប់គ្រង។

-ចំពោះការទាមទារឲ្យដើមចោទសងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន ) រៀល គឺមានចំនួនច្រើនពេក ដែលគប្បីតុលាការពិចារណា និងសម្រេចទៅតាមភាពជាក់ស្តែង និងសមហេតុផល ។

៥.តាមលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ រវាងឈ្មោះ ចក់ ស៊ីណាន និងឈ្មោះ [redacted] តុយអេង និងឈ្មោះ [redacted] ភត្រា និងលិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២-០៩-២០១៩ រវាងឈ្មោះ [redacted] តម និងឈ្មោះ [redacted] តុយអេង និងឈ្មោះ [redacted] ភត្រា ស្ថិតនៅភូមិសំពៅង ឃុំព្នាយ ស្រុកសំរោងទង

ខេត្តកំពង់ស្ពឺ  អាចបញ្ជាក់ថាសហចុងចម្លើយពិតជាបានទិញដីពីឈ្មោះ [redacted] ភក្តី និងមានការផ្ទេរកម្មសិទ្ធិពីម្ចាស់ដីដើមប្រាកដមែន។

១០.យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១.ច្រានចោលការទាមទារទាំងអស់របស់ដើមចោទឈ្មោះ ហង់ ចាន់ថុល ។

២.ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភក្តី ដែលបានលក់ដីមកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] គុយអេង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:០៥០៧០៥១៨-០៥៥០ មានទំហំ៥០៨ម$^{២}$ មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

៣.ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងលក់ផ្តាច់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភក្តី ដែលបានលក់ដីមកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] គុយអេង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ ៧៤៥ ម$^{២}$ មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

៤.ប្រគល់ដីចំនួន០២កន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥០ មានទំហំ៥០៨ម$^{២}$ និងដីមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៥០៧០៥១៨-០៥៥២ មានទំហំ៧៤៥ម$^{២}$ មានទីតាំងស្ថិតនៅភូមិសំពៅង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មកឲ្យឈ្មោះ [redacted] ភត្រា និងប្រពន្ធឈ្មោះ [redacted] គុយអេង ជាអ្នកគ្រប់គ្រង។

៥.ឲ្យដើមចោទសងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន ២.០០០.០០០ (ពីរលាន) រៀល មកឲ្យឈ្មោះ [redacted] ភត្រា និងឈ្មោះ [redacted] គុយអេង។ ច្រានចោលការទាមទារលើសពីនេះ។

៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះត្រូវប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល០១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃសុក្រ ២រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅខេត្តកំពង់ស្ពឺ, ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ២រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅខេត្តកំពង់ស្ពឺ, ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]